# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ១៩ ស.ស.រ**

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារ

## ទទួលបន្ទុកដោះស្រាយបញ្ហាការកាប់បំផ្លាញដីព្រៃឈើគ្រប់ប្រភេទរបស់រដ្ឋយកធ្វើជាកម្មសិទ្ធិ នៅខេត្តស្ទឹងត្រែង

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៧០៤/ ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- សេចក្តីសំរេចរបស់អង្គប្រជុំអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៦
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ២០០៦។

## សម្រេច

**ប្រការ ១.-** បង្កើតក្រុមការងារមួយដើម្បីចុះត្រួតពិនិត្យ និងដោះស្រាយបញ្ហាការកាប់បំផ្លាញដីព្រៃឈើ និងការទន្ទ្រានកាន់កាប់ដីព្រៃឈើគ្រប់ប្រភេទធ្វើជាកម្មសិទ្ធិនៅខេត្តស្ទឹងត្រែង ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១- | លោកជំទាវ **ម៉ែន សំអន** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច និងជាអនុប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | ប្រធាន |
| ២- | ឯកឧត្តម **គន់ គីម** | អគ្គមេបញ្ជាការរង នៃកងយោធពលខេមរៈភូមិន្ទ | អនុប្រធាន |
| ៣- | ឯកឧត្តម **ចំនួ សារុន** | រដ្ឋមន្ត្រីក្រសួងកសិកម្ម | អនុប្រធាន |
| ៤- | ឯកឧត្តម **សៅ សុខា** | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៥- | ឯកឧត្តម **ជុំ ម៉ិន រ៉ុង** | តំណាងឯកឧត្តមប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី | សមាជិក |
| ៦- | ឯកឧត្តម **ទី សុគន្ធ** | ប្រធានរដ្ឋបាលព្រៃឈើ | សមាជិក |

៧- ឯកឧត្តម **ឆាំង ចន្ទតារា** អគ្គលេខាធិការរងនៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី សមាជិក

៨- ឯកឧត្តម **ឆែ ស៊ីណារិទ្ធ** អគ្គលេខាធិការរងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី សមាជិក

៩- លោក **សួន ស៊ីផាត** តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

១០- លោក **ឈិត សារិទ្ធ** អគ្គលេខាធិការរងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី សមាជិក

**ប្រការ ២.-** ក្រុមការងារនេះមានភារកិច្ចដូចតទៅ :

១- វាយតំលៃ និងត្រួតពិនិត្យការអនុវត្តន៍ច្បាប់ និងលិខិតបទដ្ឋាននានាពាក់ព័ន្ធនឹងដីព្រៃឈើគ្រប់ប្រភេទ ដែលមានជាធរមាន ជាពិសេសការអនុវត្តន៍បទបញ្ជាដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចនាយករដ្ឋមន្ត្រី ស្តីពីការទប់ស្កាត់ ការកាប់រានដីព្រៃឈើគ្រប់ប្រភេទរបស់រដ្ឋយកធ្វើជាកម្មសិទ្ធិ ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៦ ដែលណែនាំអោយអភិបាលខេត្ត- ក្រុង អោយប្រើអំណាចរដ្ឋចេញដីការជាបន្ទាន់ប្រកាសបដិសេធ និងដកហូតដីព្រៃគ្រប់ប្រភេទ ដែលត្រូវបានរំលោភទាំងអស់មកទុកជាសម្បត្តិរដ្ឋវិញ តាមការចាំបាច់ ។

២- រៀបចំវិធានការណ៍ចាំបាច់មួយចំនួនសំដៅ អប់រំ ទប់ស្កាត់ និងដោះស្រាយបញ្ហាកាប់បំផ្លាញព្រៃឈើ និងការទន្ទ្រានកាន់កាប់ដីព្រៃឈើធ្វើជាកម្មសិទ្ធិ នៅខេត្តស្ទឹងត្រែង ជាពិសេសការអនុវត្តន៍អនុក្រឹត្យស្តីពីដីសម្បទានសង្គមកិច្ច ។

៣- ធ្វើរបាយការណ៍អំពីលទ្ធផលការងារ និងលើកយោបល់ជូនអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ដើម្បីរាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ ៣.-** សមាជិកក្រុមការងារទាំងអស់ត្រូវចូលរួមការប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៤.-** រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គ្រប់ក្រសួង ស្ថាប័ន អភិបាលខេត្ត ក្រុង ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
- អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
-គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
-សាលាខេត្តស្ទឹងត្រែង
-ដូចប្រការ ៤
-ឯកសារ-កាលប្បវត្តិ